# បដិមាព្រះហរិហរនៅសំបូរព្រៃគុក

ហរិហរ គឺជាទេពដែលលាយបញ្ចូលគ្នានៅក្នុងព្រហ្មញ្ញសាសនារវាងព្រះវិស្ណុ និងព្រះសិវ (ហរិ + ហរ)។ ជួនកាលគេហៅទេពនេះថា "សង្ករនារាយណ" ដែល សង្ករ សំដៅដល់ព្រះសិវ និង នារាយណ សំដៅដល់ព្រះវិស្ណុវិញ ហើយជាទម្រង់កំពូលនៃទេពដែលមានឆ្លាក់នៅតាមជញ្ជាំងប្រាសាទមួយចំនួនក្នុងប្រទេសឥណ្ឌាតាំងពីស.វ.ទី៦មកម្ល៉េះ[១] ក្រៅពីនេះក៏មានព្រះនាមជាច្រើនទៀតដែលគេហៅរួមបញ្ចូលគ្នារវាងទេពទាំងពីរ។ នៅតំបន់ប្រាសាទសំបូរព្រៃគុក យើងឃើញមានប្រាសាទមួយតម្កល់អាទិទេពហរិហរ ពោល គឺស្ថិតនៅក្រុមប្រាសាទសំបូរ ឬក្រុមខាងជើង (តួប៉ម N10)។ តើបដិមាព្រះហរិហរ និងប្រាសាទតម្កល់ទេពអង្គនេះមានលក្ខណៈបែបណាខ្លះ?

មុននឹងបរិយាយអំពីលក្ខណៈជាទូទៅនៃបដិមាព្រះហរិហរ និងប្រាសាទតម្កល់ទេពអង្គនេះនៅសំបូរព្រៃគុក យើងសូមបង្ហាញដោយសង្ខេបអំពីដំណើររឿងទេពកថាដែលមានទេពអង្គនេះឡើង។ រឿងទេវកថានេះមាននិទាននៅក្នុងរឿងព្រះក្រឹស្ណដែលចារឹកនៅក្នុងគម្ពីរសិវបុរាណ និងគម្ពីរវុទ្រសម្ហិតា។ រឿងនោះដំណាលថា៖ "*ព្រះក្រឹស្ណដែលជាអវតាររបស់ព្រះវិស្ណុមានចៅប្រុសម្នាក់ព្រះនាម អនរុធ ដែលមានរូបរាងស្រស់សង្ហា និងមាននារីៗលួចប្រតិព័ទ្ធចិត្តជាច្រើន ហើយព្រះឥន្ទ្រដែលជាស្ដេចនៅស្ថានសួគ៌បានតែងតាំងព្រះអនរុធជាពជទូតនៅស្ថានសួគ៌ទៀតផង។ គ្រាមួយព្រះអនរុធ យាងទៅស្ថានសួគ៌ ធ្វើឱ្យស្រីសួគ៌ជាច្រើនភ្ញាក់ផ្អើលនឹងភាពស្រស់សង្ហាររបស់ទ្រង់ ហើយនាងៗបេតីទ្រង់គ្រប់ៗគ្នា ប៉ុន្តែព្រះអនរុធពុំចាប់ព្រះហឫតីនឹងស្រីសួគ៌ទាំងនោះឡើយ។ ដោយកើតមានការអន់ចិត្ត ក្រុមស្រីសួគ៌ទាំងនោះបានប្រើល្បិចសណ្ដំព្រះអនរុធឱ្យសន្ទប់ ហើយយកព្រះអនរុធទៅកាន់នគរបស (Nagapasha) ដែលជានគររបស់យក្សមានអំណាចម្នាក់ឈ្មោះថា បន (Pana) ហើយដាក់ព្រះអនរុធនៅក្នុងបន្ទប់បុត្រីរបស់យក្សបនឈ្មោះថា ឧស (Usha) ព្រោះដែលមានសម្រស់ស្រស់ស្អាត ដើម្បីចង់ពិសោធព្រះអនរុធថា តើទ្រង់មានប្រតិកម្មបែបណានៅពេលបានជួបនារីដ៏ស្រស់ស្អាត។ ជួនចៃដន្យក្នុងពេលនោះនៅនគរបស យក្សឈ្មោះ បន បានគ្រោងរៀបចំពិធីចម្រើនព្រះជន្មបុត្ររបស់ខ្លួន ហើយចង់រកព្រះស្វាមីជូនបុត្ររបស់ខ្លួនទៀតផង។ មុនដល់ថ្ងៃពិធីមួយថ្ងៃស្រីសួគ៌បានសណ្ដំយក្សទាំងអស់ឱ្យដេកលក់ ហើយបានយកព្រះអនរុធទៅដាក់នៅក្នុងបន្ទប់ព្រះនាងឧស ដោយដាក់ទ្រង់ថើបព្រះនាងឧស ហើយព្រះនាងឧសវិញផ្ទុំដោយយកព្រះហស្តឱបព្រះអនរុធ រីឯស្រីសួគ៌ទាំងអស់នៅចាំលបមើល។ ពេលព្រះនាងឧសដឹង*

[១] Alice 1990.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ព្រះកាយ ក៏រៀបនឹងហាមាត់ស្រែក ព្រះអនរុធក៏យកមាត់មកខ្ទប់មាត់ព្រះនាងឧសកុំឱ្យស្រែក។ បុត្រីយក្សឃើញព្រះអនរុធស្រស់សង្ហាក៏ស្ទុះឱបព្រះអនរុធ តែព្រះអនរុធបានរើបំរះបំណាងរត់គេច តែត្រូវព្រះនាងឧសឃាត់ទុកមិនឱ្យយាងទៅណាឡើយ។ លុះដល់ថ្ងៃពិធី យក្សទាំងអស់រង់ចាំដល់វេលាថ្ងៃត្រង់នៅតែមិនឃើញព្រះនាងចេញមកធ្វើឱ្យពួកយក្សកំលោះៗដែលចង់ឃើញព្រះនាងមានចិត្តខឹង តែបានយក្សបនជាបិតាលួងលោមយក្សទាំងនោះ ហើយទ្រង់ក៏សួរទៅនាងកិលៀង។ ក្រោយដឹងរឿងសព្វបែបយ៉ាង យក្សបនមានព្រះទ័យខ្ញាល់យ៉ាងខ្លាំង ក៏ស្ទុះទាញវត្ថុទិព្វដែលព្រះឥសូរប្រទានដល់ខ្លួនទៅជួបព្រះអនរុធ។ ពេលទៅដល់យក្សបនឃើញបុត្រីរបស់ខ្លួននៅជាមួយព្រះអនរុធ ទ្រង់កាន់តែខ្ញាល់ក៏បានចាប់ឃុំឃាំងព្រះអនរុធនៅក្នុងទ្រុងមួយដែលជាវត្ថុទិព្វព្រះឥសូរប្រទានដល់ខ្លួន ហើយសែងយកទៅដាក់មុខប្រាសាទមួយដោយក្នុងរយៈពេលប្រាំពីរថ្ងៃព្រះអនរុធនឹងរលាយក្លាយទៅជាទឹក។ ស្រីសួគ៌ក័យពេក ក៏នាំគ្នាទៅទូលព្រះក្រឹស្នឱ្យទៅជួយដល់ចៅរបស់ទ្រង់។ ព្រះក្រឹស្ន និងពលរាមជាម្ចាស់បង ក៏បានទៅដល់នគរបស ជួយរំដោះចៅរប់ខ្លួន ព្រមទាំងបានប្រយុទ្ធគ្នាជាមួយយក្សបន។ យក្សបនបានប្រែកាយជាភ្លើងឆេះកាល្បដែលមិនអាចយកទឹកណាមកពន្លត់បាន តែព្រះក្រឹស្នប្រាប់បក្សីគ្រុឌរបស់ទ្រង់ហោះទៅស្រង់ទឹកទន្លេគង្គា តែនៅមិនអាចពន្លត់ភ្លើងនោះបាន។ យក្សបន បានគំរាមថានឹងយកភ្លើងដុតស្ថានសួគ៌ចោល ដោយសារខ្លួនស្អប់ពួកអាទិទេពដែលលួចយកទឹកអម្រឹតពីពួកអសុរ។ ព្រះក្រឹស្នក៏បែងភាគទៅជាព្រះវិស្ណុដែលមានព្រះសិរច្រើន រីឯយក្សបនក៏បានបោះដំបងទិព្វមួយរបស់មេទ័ពម្នាក់ឈ្មោះ វិជយកា ទៅជាប់ដំបូលមេកើតចេញជាកងទ័ពជាច្រើនសំញ៉ែងដល់ទ័ពព្រះពលរាម។ ព្រះក្រឹស្នក៏បានប្រាប់ឱ្យព្រះពលរាមចោលនង្គ័លទិព្វរបស់សំដៅទៅផ្ទប់ជាមួយដំបងមេទ័ពវិជយកា ធ្វើឱ្យកងទ័ពយក្សរលាយក្លាម រីឯវិជយកាក៏ត្រូវដំបងរបស់ខ្លួនរលាយក្លាយជាដីនៅស្ថានមនុស្ស។ ពេលនោះទេពនិករទាំងពួងសប្បាយចិត្តយ៉ាងខ្លាំង ក៏ប្រទានងារជំមួយដល់ព្រះពលរាមថាជាប្រមុខនៃពិធីច្រត់ព្រះនង្គ័លទាំងនៅស្ថានសួគ៌និងនៅស្ថានមនុស្ស។ ចំណែកព្រះក្រឹស្នក៏បានសំដែងបដិហាជាអង្គវិស្ណុ កាត់ដៃទាំងមួយពាន់របស់យក្សបន ហើយបានកាត់ទ្រុងទិព្វរបស់ព្រះសិវរំដោះព្រះអនរុធចេញ។ ព្រះក្រឹស្នបានចាប់សង្កត់កយក្ស និងលើកយកព្រះខ័ននៃព្រះវិស្ណុគឺស័ង្ខរ ធ្វើឱ្យមេឃមួយចំហៀងងងឹត មួយចំហៀងភ្លឺ ប្រុងកាត់ក្បាលយក្សបន ព្រះសិវក៏មកដល់។ ព្រះសិវក៏មានបន្ទូលថា សូមទ្រង់កុំសម្លាប់យក្សនេះអី ព្រោះគេជាសិស្សសំណព្វរបស់យើង។ ព្រះក្រឹស្នដែលជាអវតាររបស់ព្រះវិស្ណុតបវិញថា យើងមិនឈប់ទេ យើងនឹងកាត់ក្បាលកូនសិស្សរបស់ទ្រង់ ព្រោះគេបានគំរាមដល់ស្ថានទាំងបី យើងធ្វើដើម្បីសង្គ្រោះស្ថានទាំងបីទេ។ ព្រះសិវក៏តបវិញ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ថា លើកលែងទោសឱ្យកូនសិស្សយើងម្តងទៅ ព្រះអង្គចង់បានអីក៏យើងព្រមឱ្យដែរ។ ព្រះក្រឹស្ណតបថា ចាប់ពីពេលនេះទៅ សូមទ្រង់ប្រាប់ទៅស្ថានទាំងបីថា ខ្ញុំម្ចាស់ក៏ជាអាទិទេពបង្កើតលោកទាំងបីដូចព្រះអង្គដែរ បើព្រះអង្គធ្វើបានខ្ញុំម្ចាស់នឹងទុកជីវិតដល់យក្សនេះ។ ពេលនោះព្រះសិវក៏យល់ព្រម ហើយព្រះក្រឹស្ណក៏ប្រាប់ឱ្យព្រះសិវបែងភាគមួយចំហៀង ហើយទ្រង់ផ្ទាល់ក៏បែងភាគមួយចំហៀងចូលគ្នា។ ម្ល៉ោះហើយ ទើបមានការបញ្ចូលគ្នារវាងទេពទាំងពីរនេះឡើង ដែលគេប្រសិទ្ធនាមថា "ហរិហរ" ចាប់ពីពេលនោះមក។

បដិមាព្រះហរិហរដែលតម្កល់នៅក្នុងតួប៉ម N10 នៅតំបន់ប្រាសាទសំបូរព្រៃគុកគេតម្កល់នៅលើជើងទម្រមួយរាងបួនជ្រុងស្មើដែលផ្គុំឡើងអំពីថ្មចំនួនបួនថ្នាក់ ដែលខាងលើបង្អស់មានចំពួយបង្ហូរទឹកមន្តទៅទិសខាងលិច ហើយគ្រប់ថ្នាក់នីមួយៗសុទ្ធសឹងតែមានក្បាច់លម្អជាផ្កាច្រើនប្រភេទមានលំនាំតាមលក្ខណៈសិល្បៈឥណ្ឌា និងផ្កាទាំងអស់តំណាងឱ្យភោគផលនៃការបង្កើតលោកទាំងបី (រូបលេខ១)។ បដិមាព្រះហរិហរ[២] មានកម្ពស់ ១៦៩ សង់ទីម៉ែត្រ មានរង្វង់ជារាងក្រចកសេះសម្រាប់ទ្របដិមា រីឯកេតនភណ្ឌនៅសល់តែកងចក្រកាន់នៅព្រះហស្តខាងឆ្វេងផ្នែកខាងលើ។ ព្រះកាយមានសាច់ដុំធ្វាក់តាមលំនាំធម្មជាតិពិតៗ។ ព្រះភក្ត្រញញឹមមានភាពទន់ភ្លន់ និងមានម្រាមព្រះហស្តស្រឡូនដែលសុទ្ធសឹងជាលក្ខណៈសម្គាល់នៃរចនាបថសំបូរព្រៃគុក។ គេស្គាល់រូបនេះជាព្រះហរិហរដោយសារនៅចំហៀងព្រះសិរខាងស្តាំជាព្រះសិររបស់ព្រះសិវ គឺមានផ្នួងសក់បួងវេញឡើងលើ និងចំហៀងព្រះសិរខាងឆ្វេងពាក់មុដរាងបំពង់។ លក្ខណៈមួយទៀតគឺមានព្រះនេត្រទីបីមួយចំហៀងនៅលើថ្ងាស។ បដិមានេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបដិមាព្រះហរិហរជាច្រើនទៀតនៅសម័យមុនអង្គរ (ស.វ.ទី៧-៨) ដូចជា បដិមាព្រះហរិហរនៅប្រាសាទអាស្រមមហាឫស្សី ភ្នំដា (រូបលេខ២) បដិមាព្រះហរិហរនៅប្រាសាទអណ្តែត (រូបលេខ៣) បដិមាព្រះហរិហរនៅប្រាសាទភូមិប្រាសាទ (រូបលេខ៤) ។ល។

ចំណែក ប្រាសាទដែលតម្កល់ព្រះហរិហរនៅសំបូរព្រៃគុកវិញ (តួប៉ម N10) គឺស្ថិតនៅក្នុងក្រុមប្រាសាទសំបូរ ឬក្រុមខាងជើង ដែលស្ថិតនៅទិសអាគ្នេយ៍តួប៉មកណ្តាល N1 ដែលតម្កល់លិង្គព្រះឥស្វរព្រះនាម "ស្រីគម្ភីរេស្វរ"។ ប្រាសាទនេះ សាងសង់អំពីឥដ្ឋ មានរាងបួនជ្រុងស្មើ មានទ្វារចូលតែមួយ និងពុំមានទ្វារបញ្ឆោតឡើយ ពោល គឺគេធ្វើជញ្ជាំងលាត លម្អដោយក្បាច់សសរផ្តោបជញ្ជាំងបន្តិចបន្តួចប៉ុណ្ណោះ (រូបលេខ៥-៦)។ អ្វីដែលគួរចាប់អារម្មណ៍នោះ ប្រាសាទនេះ ពុំ

[២] Helen 2004.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បែរមុខទៅទិសខាងកើតដូចប្រាសាទផ្សេងទៀតឡើយ តែសិល្បករធ្វើបែរមុខទៅទិសខាងជើង ពោល គឺបែរមុខរកគ្នាជាមួយតួប៉មមួយទៀតដែលគេតម្កល់ទេពទុគ៌ា (តួប៉ម N9 បែរមុខទៅទិសខាងត្បូង)។ ការដែលគេសង់ប្រាសាទតម្កល់រូបព្រះហរិហរបែរមុខទៅទិសខាងជើងនេះ យើងពិបាកនឹងរកហេតុផលមកពន្យល់ណាស់ ព្រោះប្រសិនបើយើងសន្និដ្ឋានថាអាចមកពីគេយកតាមឬក្សព្រះចន្ទ្រ ឬនក្សត្រក៏ពិបាកថាដែរ។ ប៉ុន្តែបើយើងសាកល្បងពន្យល់ថា គេបែរមុខទៅរកទិសខាងជើង ដោយសារខាងជើងជាទិសលោកបាលរបស់ព្រះកុវេរ ក៏អាចម្យ៉ាងដែរ ព្រោះព្រះអង្គជាទេពនៃទ្រព្យសម្បត្តិ ឬជាទេពនៃភោគផល ម្យ៉ាងដោយសារព្រះហរិហរមានតួនាទីជាអ្នកបង្កើតលោកទាំងបីផងដែរ។ ការបែរមុខទៅទិសខាងជើងនេះ វាមានភាពដូចគ្នាជាមួយប្រាសាទអាស្រមមហាឥសី (ភ្នំដា ស្រុកអង្គរបុរី) ដែលអ្នកស្រាវជ្រាវជាច្រើនក៏ពិបាកពន្យល់ដូចគ្នា តែអ្នកខ្លះយល់ថាគេសង់តាមស្ថានភាពភូមិសាស្ត្រ។ ប៉ុន្តែ ប្រាសាទផ្សេងៗទៀតដែលតម្កល់ព្រះហរិហរដូចគ្នា ច្រើនតែបែរមុខទៅទិសខាងកើតដូចគ្នា ឧទាហរណ៍ ប្រាសាទអណ្តែត និងប្រាសាទភូមិប្រាសាទ (ខេត្តកំពង់ធំ)។

ប្រការគួរចាប់អារម្មណ៍មួយដែរនោះគឺ នៅក្នុងតួប៉មប្រាសាទនេះយើងឃើញមានថ្មមួយរាងបួនជ្រុងទ្រវែងដែលមានប្រហោងតម្កល់ទេពចំនួនប្រាំបួន ដែលលោក **ឈុំ ម៉េងហុង** យល់ថាជាថ្មដែលតម្កល់ទេពនព្វគ្រោះ ឬហៅម្យ៉ាងទៀតថា "ផ្កាយនព្វគ្រោះ"។[៣] សព្វថ្ងៃថ្មនេះបាក់ខាងចុងបន្តិច និងគេរក្សាទុកនៅក្បែរជើងទម្រព្រះហរិហរតែម្តង (រូបលេខ៧)។ ក្រៅពីនេះទៀត នៅខាងលិចតួប៉មតម្កល់បដិមាព្រះហរិហរ មានសំណង់រាងបួនទ្រវែងមួយដែលនៅជ្រុងខាងត្បូងមានស្នាកស្នាមសសរឥដ្ឋ ហើយកាលពីឆ្នាំ២០០៨ គម្រោងអភិរក្សសំបូរព្រៃគុក នៃសាកលវិទ្យាល័យវ៉ាសេដា ធ្លាប់ធ្វើកំណាយមើលពីរចនាសម្ព័ន្ធសំណង់នេះ ព្រមទាំងរកឃើញបំណែកបដិមាព្រះគណេសជាច្រើនបំណែកនៅខាងលើសំណង់នោះថែមទៀតផង។ ការដែលគេតម្កល់រូបផ្កាយនព្វគ្រោះ និងព្រះគណេស នៅក្បែរបដិមាព្រះហរិហរនេះ អាចចង់បង្ហាញថា ប្រាសាទជានិមិត្តរូបនៃស្ថានសួគ៌ ឬភ្នំមេរុដែលនៅលើផែនដី ម្ល៉ោះហើយស្ថានសួគ៌ឬស្ថាននៃទេព ក៏គួរប្រជុំគ្នាដោយទេពជុំវិញដូចគ្នា។

ជារួមមក បដិមាព្រះហរិហរដែលជាការរួមបញ្ចូលគ្នារវាងអាទិទេពព្រះវិស្ណុនិងព្រះឥសូរ នៅសំបូរព្រៃគុក គេតម្កល់នៅក្នុងតួប៉មប្រាសាទមួយ ដែលស្ថិតនៅទិសអាគ្នេយ៍តួប៉មកណ្តាលនៃក្រុមខាងជើង ហើយប្រាសាទនេះបែរមុខទៅទិសខាងជើង។ បដិមាព្រះហរិហរ គេតម្កល់នៅលើ

[៣] Chhum Menghong 2020.

ដើងទម្រមួយដែលលម្អដោយក្បាច់រុក្ខជាតិជាច្រើនប្រភេទ បង្ហាញអំពីភោគផលនៃការបង្កើតលោក ឬបង្កើតស្ថានទាំងបីរបស់ព្រះវិស្ណុនិងព្រះឥសូរ។




រូបលេខ១៖ បដិមាព្រះហរិហរនៅតំបន់ប្រាសាទសំបូរព្រៃគុក (តួប៉មN10)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ២.៣៖ បដិមាព្រះហរិហរនៅប្រាសាទអាស្រមមហាឫស្សី និងប្រាសាទអណ្តែត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ បដិមាព្រះហរិហរនៅប្រាសាទភូមិប្រាសាទ



រូបលេខ២៩៖ ប្រាសាទតម្កល់បដិមាព្រះហរិហរនៅសំបូរព្រៃគុក (តួប៉ម N10) មើលពីទិសខាងជើង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៦៖ ប្រាសាទតម្កល់បដិមាព្រះហរិហរនៅសំបូរព្រៃគុក (តួប៉ម N10) មើលពីទិសឦសាន

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ថ្មទម្រផ្កាយ ឬទេពនព្វគ្រោះ រកឃើញនៅតួប៉ម N10

## ឯកសារយោង

**Alice Boner**

1909. Principles of Composition in Hindu Sculpture: Cave Temple Period, Motilal Banarsidass, pp.89-95.

**Chhum Menghong**

2020, *Nine deities panel in ancient Cambodia, Pratu Journal of Buddhist and Hindu art*, Volume I, London.

**Helen Ibbitson Jessup**

2004, "*Art & Architecture of Cambodia*", London.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី